ព្រះរាជាណាចក្រកម្ពុជា
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# បទបង្ហាញ

## ស្តីពី

# ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

**ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨**

# មាតិកា


១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៨

២. ក្របខណ្ឌថវិកាឆ្នាំ ២០១៨

២.១ ស្ថានភាពចំណូលថវិការដ្ឋ

២.២ ស្ថានភាពចំណាយថវិការដ្ឋ

២.៣ សន្និធិបំណុលសាធារណៈក្រៅប្រទេស

២.៤ គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

៣. វិធានការ និង បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០១៨

៤. សន្និដ្ឋាន

# ១ បរិការណ៍រួមនៃការរៀបចំ ថវិកាឆ្នាំ ២០១៨

# ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៨



ឯកភាពជាតិ
និង
ទឹកដី





សុខសន្តិភាព
និង
ស្ថិរភាព
នយោបាយ

ការបោះឆ្នោតជ្រើសតាំង
សមាជិកព្រឹទ្ធសភា
និងតំណាងរាស្ត្រ
ឆ្នាំ ២០១៨

កំណើន
និង
ស្ថិរភាព
ម៉ាក្រូសេដ្ឋកិច្ច





ប្រជាធិបតេយ្យ
សិទ្ធិមនុស្ស
និង នីតិរដ្ឋ



# ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៨ (ត)

## បញ្ហាប្រឈម និង ហានិភ័យ

- សម្ពាធចំណាយថវិកា, បន្ទុកបុគ្គលិក ក្នុងខណៈ ចំណូលថវិកាកៀកនឹងពិដាននៃសក្តានុពល
- និន្នាការកើនឡើងនៃថ្លៃប្រេង និងសម្ពាធនៃថ្លៃម្ហូបអាហារ
- បញ្ហាប្រឈមផ្សេងៗ៖ ថ្លៃអគ្គិសនីខ្ពស់, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកនៅទន់ខ្សោយ, កំណើនប្រាក់ឈ្នួលអប្បបរមា, ផលិតភាពទាប និងកង្វះជំនាញ, ភាពស្មុគស្មាញ និងថ្លៃខ្ពស់នៃនិតិវិធីធុរកិច្ច




### កត្តាខាងក្រៅ

- កំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍមានកម្រិតទាប, និន្នាការនៃគោលនយោបាយគាំពារនិយមនៅបន្ត
- ភាពប្រកួតប្រជែងខ្លាំងក្នុងតំបន់ និងការដាក់ឱ្យអនុវត្ត FTA រវាងសហភាពអឺរ៉ុប និងវៀតណាម
- ការរឹតបណ្តឹងគោលនយោបាយរូបិយវត្ថុ និង ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក
- ការថមថយកំណើនសេដ្ឋកិច្ចរបស់ចិន និង ហានិភ័យនៃកំណើនខ្ពស់នៃឥណទាន
- បញ្ហាភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចក្នុងពិភពលោក...

# ១.២. ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច (២០១៦-២០១៨)

| សូចនាករសេដ្ឋកិច្ច | ២០១៦ | ២០១៧ ប៉ាន់. | ២០១៨ ព្យ. |
|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (លានរៀល) | ៨០ ៥៥៩ ៥៣២ | ៨៩ ៥០៩ ៤២២ | ៩៩ ១១៦ ០៤១ |
| ផលិតផលពិតក្នុងស្រុកសរុប (កំណើនជា%) | ៧,០% | ៦,៩% | ៦,៩% |
| វិស័យកសិកម្ម | ១,៨% | ២,០% | ២,០% |
| វិស័យឧស្សាហកម្ម | ១០,៥% | ៩,២% | ៨,៦% |
| វិស័យសេវាកម្ម | ៦,៧% | ៧,២% | ៧,៦% |
| ផសស សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | ១ ៣០២ | ១ ៤៣៥ | ១ ៥៦៨ |
| អតិផរណាជាប្រាក់រៀល (កំណើនមធ្យមប្រចាំឆ្នាំជា%) | ៣,០% | ៣,៨% | ៣,៥% |
| អត្រាប្តូរប្រាក់ (រៀល/ ដុល្លារ) | ៤ ០៥៦ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (%នៃ ផសស) (រួមបញ្ចូលបង្វែរ) | -៩,០% | -៧,៩% | -៨,៤% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៦ ៧៣១ | ៩ ០៥០ | ១០ ៥១៨ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | ៥,៥ | ៦,០ | ៦,៥ |

# ថវិកាឆ្នាំ ២០១៨ ÷

“សមិទ្ធិផលរាជរដ្ឋាភិបាល ៤ ឆ្នាំកន្លងមក និងទិសដៅការងារសម្រាប់ឆ្នាំចុង
ក្រោយនៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ឆ្ពោះទៅសម្រេចឱ្យបាន
ជាអតិបរមានូវគោលដៅសំខាន់ៗនៃ
កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល”

# ១.៣. អតិក្រម និងគោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០១៨

## ក. អតិក្រម និងគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រ

**អតិក្រមសំខាន់ៗចំនួន ២÷**

**(ទី១)**- ធានានិរន្តរភាព និង ភាពរលូននៃកិច្ចដំណើរការគ្រប់គ្រងរដ្ឋបាល និង ការដឹកនាំរាជរដ្ឋាភិបាល

**(ទី២)**- អនុវត្តបញ្ចប់ការងារសេសសល់ ដែលក្រសួង-ស្ថាប័នត្រូវបំពេញ ដើម្បីឆ្លើយតបបំណងប្រាថ្នារបស់ប្រជាជន និងការអភិវឌ្ឍ

**គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រ ចំនួន ៤**

- ធានាសម្រេចឱ្យបាននូវ កំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%
- ធានាឱ្យបាននូវស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច
- ផ្តល់ការលើកទឹកចិត្តដល់ក្រសួង ស្ថាប័នណា ដែលបុរេសកម្ម និង មានសមិទ្ធកម្ម ឬ លទ្ធផលការងារល្អ
- បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ របស់រាជរដ្ឋាភិបាល

**គោលការណ៍បច្ចេកទេស**

# ១.៣. អតិក្រម និងគោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០១៨ (ត)

## ខ. គោលការណ៍បច្ចេកទេស




**ថវិកាឆ្នាំ ២០១៨**

- ១/- ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល
- ២/- ការកំណត់លំដាប់អាទិភាព
- ៣/- ការយកចិត្តទុកដាក់លើមនុស្ស
- ៤/- កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព
- ៥/- ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត
- ៦/- ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា
- ៧/- ការរក្សាតុល្យភាព និងចីរភាពថវិកា

# ២ ក្របខណ្ឌថវិកាឆ្នាំ ២០១៨




**ត្រូវបានរៀបចំលើមូលដ្ឋាន កំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ព្រមជាមួយនឹង សេណារីយ៉ូចំណូលសុទិដ្ឋិនិយម លើមូលដ្ឋានលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូលសារពើពន្ធក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយ**

# ក្របខណ្ឌគោលនយោបាយថវិកាឆ្នាំ ២០១៨

## គោលបំណងសំខាន់ៗ

- បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ សង្គម នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ
- បន្តអនុវត្តគោលនយោបាយនានា ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព
- ធានាសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ប្រកបដោយបរិយាប័ន្ន
- រក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ
- បន្តផ្តល់អាទិភាពដល់ការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ
- គាំទ្រដល់ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥
- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និង ហានិភ័យផ្សេងៗ
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស
- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់

# ក្របខណ្ឌគោលនយោបាយថវិកាឆ្នាំ ២០១៨ (ត)

## គោលបំណងសំខាន់ៗ

- បន្តផ្តល់អាទិភាពដល់ការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាពតម្លៃបន្ថែម ជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ផលិតកម្មស្រូវនិងការនាំចេញអង្ករ
- បន្តជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥
- បន្តអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៥-២០១៨
- គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល
- ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៤ និងតំណាងរាស្ត្រ នីតិកាលទី ៦។

# លទ្ធផលនៃការអនុវត្តថវិកា ២០១៣-២០១៧

**ផ្នែកចំណូល**

- ទំហំចំណូលចរន្តថវិការដ្ឋ បានកើនឡើងប្រមាណ ពីរដង (ពី **២ ២៦៤** ដល់ **៤ ០៨០** លានដុល្លារអាមេរិក)
- ចំណូលបានកើនឡើងប្រមាណជិត ១ ពិន្ទុភាគរយនៃ ផសស ក្នុងមួយឆ្នាំ ពោលគឺលើសពីគោលដៅ ០,៥០ ពិន្ទុភាគរយនៃ ផសស និងលើសពីកម្រិត ១៦,៨១%នៃ ផសស សម្រាប់គោលដៅឆ្នាំ២០១៧ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- **ចំណូលថវិកាជាតិធៀបនឹង ផសស ឡើងដល់កម្រិតកណ្ដាលធៀបនឹងប្រទេសក្នុងតំបន់ (១៤,៨៦%នៃ ផសស ដល់ ១៨,៤០%នៃ ផសស)**

**ផ្នែកចំណាយ**

- **បង្កើនទំហំចំណាយថវិការដ្ឋសរុប ជិតពីរដង (ពី ៣ ៣៤៨ ដល់ ៥ ២៤០ លានដុល្លារអាមេរិក)**
- បង្កើនគុណភាពចំណាយតាមរយៈការបន្តបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា និងការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និងបច្ចេកទេស (ទំហំទឹកប្រាក់ដដែល តែទទួលបាននូវទំនិញ សេវា និងសំណង់ ក្នុងបរិមាណច្រើនជាងមុន, គុណភាពល្អជាងមុន និងតម្រង់ចំណាយឱ្យកាន់តែចំទិសដៅ និង អាទិភាពជាងមុន)
- **ចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានបង្កើនជិតពីរដង ពី ៣១៣ ដល់ ៥៤១ លានដុល្លារអាមេរិក**



# ក្របខណ្ឌថវិការដ្ឋ (២០១៣-២០១៨)

*ឯកតា លានរៀល*



# ក្របខណ្ឌថវិការដ្ឋ (២០១៣-២០១៨) (ត)

ក្របខណ្ឌថវិការដ្ឋជា % ផសស (២០១៣-២០១៨)



# ក្របខណ្ឌថវិការដ្ឋ ២០១៨

| សូចនាករថវិកា | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណូលក្នុងប្រទេស (% ផសស) | 17.82 | 18.89 | 18.57 | 18.75 |
| - ចំណូលចរន្ត (% ផសស) | 17.66 | 18.74 | 18.40 | 18.57 |
| ចំណាយថវិការដ្ឋសរុប (% ផសស) | 22.70 | 22.03 | 23.63 | 24.59 |
| - ចំណាយចរន្ត (% ផសស) | 14.68 | 14.28 | 15.42 | 16.09 |
| អតិរេកចរន្ត (% ផសស) | 2.98 | 4.46 | 2.98 | 2.48 |
| ឱនភាពសរុប (% ផសស) | -4.87 | -3.13 | -5.07 | -5.84 |

# ២ ក្របខណ្ឌថវិកាឆ្នាំ ២០១៨

## ២.១ ស្ថានភាពចំណូលថវិការដ្ឋ

**បានរៀបចំឡើងតាមសេណារីយ៉ូ សុទិដ្ឋិនិយម លើមូលដ្ឋានលទ្ធផលចំណូលល្អប្រសើរ ៤ឆ្នាំមកនេះ**

# ចំណូលក្នុងប្រទេស (២០១៣-២០១៨)

ឯកតា លានរៀល



# ចំណូលចរន្តថ្នាក់ជាតិ ជាពិសេស ចំណូលសារពើពន្ធរំពឹងថានឹងបន្តកើន ឡើងប្រសើរជាងយុទ្ធសាស្ត្រកៀរគរចំណូល

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. |
| **ចំណូលចរន្តថវិកាថ្នាក់ជាតិ** | **14,277,623** | **15,501,469** | **17,460,006** | **16.6%** | **8.6%** | **12.6%** | **17.72%** | **17.32%** | ***17.62%** |
| +ចំណូលសារពើពន្ធ | 12,197,748 | 13,209,100 | 15,075,562 | 12.5% | 8.3% | 14.1% | 15.14% | 14.76% | 15.21% |
| -គយ និងរដ្ឋាករ | 6,946,861 | 7,309,000 | 8,330,004 | 14.0% | 5.2% | 14.0% | 8.62% | 8.17% | 8.40% |
| -ពន្ធដារ | 5,250,886 | 5,900,100 | 6,745,558 | 18.1% | 12.4% | 14.3% | 6.52% | 6.59% | 6.81% |
| +ចំណូលមិនមែនសារពើពន្ធ | 2,079,875 | 2,292,369 | 2,384,444 | 48.0% | 10.2% | 4.0% | 2.58% | 2.56% | 2.41% |

* ទំហំ**ចំណូលចរន្តថ្នាក់ជាតិ**កើនលើសគោលដៅ**ចំណូលចរន្តសរុប** **(ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ)** ដែលបានកំណត់ក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម** ត្រឹមតែ **១៧,៣៥%** នៃ ផសស សម្រាប់ឆ្នាំ២០១៨ ។

# ចំណូលប្រមាណជិត ៥០% នៃចំណូលចរន្តថ្នាក់ជាតិ ត្រូវបានប្រមូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និង ប្រមាណជិត ៤០% ប្រមូលដោយ អគ្គនាយកដ្ឋានពន្ធដារ



# ចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ ២០១៨

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. |
| **ចំណូលចរន្តថវិកាថ្នាក់ជាតិ** | **14,277,623** | **15,501,469** | **17,460,006** | **16.6%** | **8.6%** | **12.6%** | **17.72%** | **17.32%** | **17.62%** |
| + ចំណូលសារពើពន្ធ | 12,197,748 | 13,209,100 | 15,075,562 | 12.5% | 8.3% | 14.1% | 15.14% | 14.76% | 15.21% |
| - ពន្ធផ្ទាល់ | 2,952,788 | 3,276,600 | 3,899,300 | 19.4% | 11.0% | 19.0% | 3.67% | 3.66% | 3.93% |
| - ពន្ធប្រយោល | 9,244,960 | 9,932,500 | 11,176,262 | 10.5% | 7.4% | 12.5% | 11.48% | 11.10% | 11.28% |
| + ចំណូលមិនមែនសារពើពន្ធ | 2,079,875 | 2,292,369 | 2,384,444 | 48.0% | 10.2% | 4.0% | 2.58% | 2.56% | 2.41% |

# ពន្ធផ្ទាល់នៅមានសក្តានុពលសម្រាប់ពង្រីក



# ចំណូលចរន្តថវិកាថ្នាក់ជាតិ ឆ្នាំ ២០១៨

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 អនុ | 2017 ច្ប. | 2018ច្ប. | 2016 អនុ | 2017 ច្ប. | 2018ច្ប. | 2016 អនុ | 2017 ច្ប. | 2018ច្ប. |
| **ចំណូលចរន្តថវិកាថ្នាក់ជាតិ** | **14,277,623** | **15,501,469** | **17,460,006** | **16.6%** | **8.6%** | **12.6%** | **17.72%** | **17.32%** | **17.62%** |
| +ចំណូលសារពើពន្ធ | 12,197,748 | 13,209,100 | 15,075,562 | 12.5% | 8.3% | 14.1% | 15.14% | 14.76% | 15.21% |
| -ពន្ធក្នុងប្រទេស | 10,187,623 | 11,009,500 | 12,934,062 | 13.7% | 8.1% | 17.5% | 12.65% | 12.30% | 13.05% |
| -ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2,010,125 | 2,199,600 | 2,141,500 | 7.1% | 9.4% | -2.6% | 2.50% | 2.46% | 2.16% |
| +ចំណូលមិនមែនសារពើពន្ធ | 2,079,875 | 2,292,369 | 2,384,444 | 48.0% | 10.2% | 4.0% | 2.58% | 2.56% | 2.41% |

# ពន្ធក្នុងប្រទេសជាប្រភពចំណូលសារពើពន្ធដ៏សំខាន់



# ចំណូលមូលធន ឆ្នាំ ២០១៨

| ចំណូល | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. |
| **ចំណូលមូលធន** | **4,238,085** | **4,682,988** | **4,977,132** | **6.4%** | **10.5%** | **6.3%** | **5.26%** | **5.23%** | **5.02%** |
| ក្នុងប្រទេស | 119,900 | 148,431 | 180,193 | -1.2% | 23.8% | 21.4% | 0.15% | 0.17% | 0.18% |
| ក្រៅប្រទេស | 4,118,186 | 4,534,557 | 4,796,939 | 6.6% | 10.1% | 5.8% | 5.11% | 5.07% | 4.84% |
| + មូលនិធិទ្រទ្រង់ថវិកា | 286,935 | 250,000 | 250,000 | 102.4% | -12.9% | 0.0% | 0.36% | 0.28% | 0.25% |
| + មូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 3,831,250 | 4,284,557 | 4,546,939 | 3.0% | 11.8% | 6.1% | 4.76% | 4.79% | 4.59% |
| -អំណោយផ្សេងៗ | 1,834,592 | 599,838 | 591,102 | 31.6% | -67.3% | -1.5% | 2.28% | 0.67% | 0.60% |
| -ការខ្ចី | 1,996,658 | 3,684,719 | 3,955,837 | -14.2% | 84.5% | 7.4% | 2.48% | 4.12% | 3.99% |

# សូចនាករគន្លឹះនៃយុទ្ធសាស្ត្រកៀរគរចំណូល (២០១៤-២០១៨)

| ចំណូលចរន្ត (ពាន់លានរៀល) | ច្ប.២០១៤ | ពព្រ.២០១៥ | ពព្រ.២០១៦ | ពព្រ.២០១៧ | ពព្រ.២០១៨ |
|---|---|---|---|---|---|
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 4,634 | 5,271 | 5,926 | 6,657 | 7,461 |
| អគ្គនាយកដ្ឋានពន្ធដារ | 3,974 | 4,658 | 5,419 | 6,275 | 7,215 |
| ចំណូលមិនមែនសារពើពន្ធ | 1,677 | 1,750 | 1,960 | 2,210 | 2,486 |
| **ចំណូលចរន្តសរុប** | **10,284** | **11,679** | **13,306** | **15,142** | **17,162** |
| **កំណើនប្រចាំឆ្នាំ** | | | | | |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 13.4% | 13.8% | 12.4% | 12.3% | 12.1% |
| អគ្គនាយកដ្ឋានពន្ធដារ | 12.2% | 17.2% | 16.3% | 15.8% | 15.0% |
| ចំណូលមិនមែនសារពើពន្ធ(*) | 16.3% | 4.3% | 12.0% | 12.7% | 12.5% |
| **ចំណូលចរន្តសរុប** | **13.4%** | **13.6%** | **13.9%** | **13.8%** | **13.3%** |
| **ភាគរយនៃផសស** | | | | | |
| អគ្គនាយកដ្ឋានគយ | 6.85% | 7.08% | 7.24% | 7.39% | 7.54% |
| អគ្គនាយកដ្ឋានពន្ធដារ | 5.87% | 6.26% | 6.62% | 6.97% | 7.29% |
| ចំណូលមិនមែនសារពើពន្ធ | 2.48% | 2.35% | 2.40% | 2.45% | 2.51% |
| **ចំណូលចរន្តសរុប** | **15.18%** | **15.69%** | **16.26%** | **16.81%** | **17.35%** |
| **កំណើនចំណូលចរន្តជាភាគរយនៃផសស** | **0.44** | **0.51** | **0.57** | **0.55** | **0.54** |

# ២ ក្របខណ្ឌថវិកាឆ្នាំ ២០១៨

## ២.២ ស្ថានភាពចំណាយថវិការដ្ឋ

**បានរៀបចំឡើងតាមគោលនយោបាយវិត្ថារកម្មថវិកាដោយប្រយ័ត្នប្រយែង**
**ដោយផ្ដោតការយកចិត្តទុកដាក់ ជាពិសេសលើមនុស្ស**

# ចំណាយចរន្តថវិការដ្ឋ កើនឡើងខ្លាំងនៅឆ្នាំ ២០១៨



# ចំណាយបន្ទុកបុគ្គលិកបន្តកើនឡើង បង្កើនជាសម្ពាធ
# នៅលើចំណាយមិនមែនបុគ្គលិក និង វិនិយោគ

| ចំណាយ | ឯកតាលានរៀល | | | កំណើនប្រចាំឆ្នាំ | | | % ផសស | | |
|---|---|---|---|---|---|---|---|---|---|
| | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. | 2016 អនុ | 2017 ច្ប. | 2018 ច្ប. |
| **ចំណាយថវិការដ្ឋសរុប** | **17,743,887** | **21,151,985** | **24,375,102** | **15.8%** | **19.2%** | **15.2%** | **22.03%** | **23.63%** | **24.59%** |
| **-ចំណាយចរន្តថវិការដ្ឋ** | **11,506,075** | **13,799,079** | **15,945,418** | **20.6%** | **19.9%** | **15.6%** | **14.28%** | **15.42%** | **16.09%** |
| បន្ទុកបុគ្គលិក | 5,798,890 | 7,134,388 | 8,302,968 | 22.6% | 23.0% | 16.4% | 7.20% | 7.97% | 8.38% |
| មិនមែនបន្ទុកបុគ្គលិក | 5,707,185 | 6,664,691 | 7,642,451 | 18.6% | 16.8% | 14.7% | 7.08% | 7.45% | 7.71% |
| **-ចំណាយមូលធនថវិការដ្ឋ** | **6,237,812** | **7,352,906** | **8,429,684** | **7.8%** | **17.9%** | **14.6%** | **7.74%** | **8.21%** | **8.50%** |
| +វិនិយោគសាធារណៈ ហិរញ្ញប្បទានក្នុងប្រទេស | 1,943,515 | 2,402,835 | 3,145,352 | 12.0% | 23.6% | 30.9% | 2.41% | 2.68% | 3.17% |
| *-មូលនិធិទ្រទ្រង់ថវិកា* | *137,065* | *250,000* | *250,000* | -23.0% | 82.4% | 0.0% | *0.17%* | *0.28%* | *0.25%* |
| +វិនិយោគសាធារណៈ ហិរញ្ញប្បទានក្រៅប្រទេស | 3,831,250 | 4,284,557 | 4,546,939 | 3.0% | 11.8% | 6.1% | 4.76% | 4.79% | 4.59% |

# ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ ឡើងលើស ៥០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ

*ឯកតា លានរៀល*

| គម្រោងចំណាយ | 2017 ច្បាប់ | 2018 ច្បាប់ | កំណើន | សមាមាត្រ | %ផសស |
|---|---|---|---|---|---|
| **ចំណាយចរន្តថវិការដ្ឋ** | **13,799,079** | **15,945,418** | **15.6%** | **100.0%** | **16.09%** |
| បន្ទុកបុគ្គលិក | 7,134,388 | 8,302,968 | 16.4% | 52.1% | 8.38% |
| មិនមែនបន្ទុកបុគ្គលិក | 6,664,691 | 7,642,451 | 14.7% | 47.9% | 7.71% |
| **-ថវិកាថ្នាក់ជាតិ** | **13,050,686** | **15,218,166** | **16.6%** | **95.4%** | **15.35%** |
| បន្ទុកបុគ្គលិក | 6,804,059 | 7,914,924 | 16.3% | 52.0% | 7.99% |
| មិនមែនបន្ទុកបុគ្គលិក | 6,246,627 | 7,303,243 | 16.9% | 48.0% | 7.37% |
| **-ថវិកាថ្នាក់ក្រោមជាតិ** | **1,386,579** | **1,465,122** | **5.7%** | **9.2%** | **1.48%** |
| បន្ទុកបុគ្គលិក | 330,329 | 388,044 | 17.5% | 26.5% | 0.39% |
| មិនមែនបន្ទុកបុគ្គលិក | 1,056,250 | 1,077,078 | 2.0% | 73.5% | 1.09% |

# ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ ធំជាង ចំណាយមិនមែនបន្ទុកបុគ្គលិក

*ឯកតា លានរៀល*



# គោលនយោបាយបៀវត្សថ្នាក់ជាតិ ឆ្នាំ ២០១៨

**ជារួម នៅឆ្នាំ ២០១៨ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានកើនឡើងជិត ៣ ដង ធៀបនឹង ឆ្នាំ ២០១៣**

**បៀវត្សអប្បបរមានឹងត្រូវបានដំឡើងដូចខាងក្រោម ÷**

- **មន្ត្រីរាជការស៊ីវិល ÷** ពីប្រមាណ ៨៥៣ ៥០០ រៀល ឆ្នាំ២០១៧ ដល់ប្រមាណ **៩១៤ ៤៥០ រៀល** នៅខែមករា ឆ្នាំ២០១៨, ចាប់ពីខែមេសា ឆ្នាំ២០១៨ ឡើងដល់ប្រមាណ **១ ០១៤ ៤៥០ រៀល** **(ឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៨៤ ០០០ រៀលប៉ុណ្ណោះ)**
- **គ្រូបង្រៀន ÷** ពីប្រមាណ ៩៥៣ ៥០០ រៀល ឆ្នាំ២០១៧ ដល់ប្រមាណ **១ ០១៤ ៤៥០ រៀល** នៅខែមករា ឆ្នាំ២០១៨, ចាប់ពីខែមេសា ឆ្នាំ២០១៨ ឡើងដល់ប្រមាណ **១ ១១៤ ៤៥០ រៀល** **(ឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៤០០ ០០០ រៀលប៉ុណ្ណោះ)**
- **គ្រូពេទ្យ÷** ពីប្រមាណ ៩៥៣ ៥០០ រៀល ឆ្នាំ២០១៧ ដល់ប្រមាណ **១ ០១៤ ៤៥០ រៀល** នៅខែមករា ឆ្នាំ២០១៨ , ចាប់ពី ខែមេសា ឆ្នាំ២០១៨ ឡើងដល់ប្រមាណ **១ ១១៤ ៤៥០ រៀល** **(ឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៦០ ០០០ រៀលប៉ុណ្ណោះ)**
- **នគរបាលជាតិ (ពលបាលត្រី)÷** ពីប្រមាណ **៩៣៧ ៩៧៧ រៀល** (ដោយគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០១៧ ទៅប្រមាណ **៩៩៨ ៩២៧ រៀល** (ដោយគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ២០១៨, ចាប់ពី ខែមេសា ឆ្នាំ២០១៨ ឡើងដល់ប្រមាណ **១ ០៩៨ ៩២៧ រៀល** (គិតបញ្ចូលរបបអង្គរ) **(ឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣៨០ ០០០ រៀលប៉ុណ្ណោះ)**
- **យោធិន (ពលទោ) ÷** ពីប្រមាណ ៨២២ ៥០០ រៀល នៅឆ្នាំ ២០១៧ ដល់ប្រមាណ **៨៧៦ ៥៥០ រៀល** នៅខែមករា ឆ្នាំ ២០១៨ (មិនគិតបញ្ចូលរបបអង្គរ), ចាប់ពី ខែមេសា ឆ្នាំ ២០១៨ ឡើងដល់ប្រមាណ **៩៧៦ ៥៥០ រៀល** (មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរត្រូវជាប្រមាណ **១ ០៣៥ ០២៧ រៀល** **(ឆ្នាំ ២០១៣ បៀវត្សនេះមានត្រឹម ៣១៦ ០០០ រៀលប៉ុណ្ណោះ)**

# គោលនយោបាយបៀវត្សថ្នាក់ក្រោមជាតិឆ្នាំ ២០១៨

- **ក្រុមប្រឹក្សារាជធានី ខេត្ត÷** ដំឡើងប្រាក់ឧបត្ថម្ភប្រធាន ពី **១,២១លានរៀល** ដល់ **១,៣៦លានរៀល** និងសមាជិកពី**៩៧ម៉ឺនរៀល** ដល់ **១,០៨លានរៀល** ចាប់ពីខែមេសា ២០១៨
- **ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ÷** ដំឡើងប្រាក់ឧបត្ថម្ភប្រធាន ពី**៩៣,៥ម៉ឺនរៀល** ដល់ **១,០៧លានរៀល** និងសមាជិក ឡើងពី**៧៥ម៉ឺនរៀល** ដល់ **៨៦ម៉ឺនរៀល** ចាប់ពីខែមេសា២០១៨
- **ក្រុមប្រឹក្សាឃុំ សង្កាត់÷** ដំឡើងប្រាក់ឧបត្ថម្ភប្រធានពី**៨៨ម៉ឺនរៀល** ដល់ **១,០៣លានរៀល**,ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ ពី **៦៥ម៉ឺនរៀល** ដល់ **៨០ម៉ឺនរៀល** និងសមាជិកពី **៥៧ម៉ឺនរៀល** ដល់ **៧០ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៨
- **មេភូមិ÷** ដំឡើងប្រាក់ឧបត្ថម្ភប្រធាន ពី **២២,៥ម៉ឺនរៀល** ដល់ **២៥ម៉ឺនរៀល** ,ជំនួយការភូមិ ពី **១៨ម៉ឺនរៀល** ដល់ **២០ម៉ឺនរៀល**, និង សមាជិក ពី **១៦ម៉ឺនរៀល** ដល់ **១៨ម៉ឺនរៀល** ចាប់ពីខែមេសា ២០១៨

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ១ ក្រសួងអប់រំ យុវជន និងកីឡា | 2,739,913 | 3,438,008 | 25.48% | 14.10% | 3.47% |
| ចំណាយចរន្តសរុប | 2,383,673 | 2,705,457 | 13.50% | 11.10% | 2.73% |
| ចំណាយមូលធនសរុប | 356,240 | 732,551 | 105.63% | 3.01% | 0.74% |
| -ក្នុងប្រទេស | 90,000 | 420,000 | 366.67% | 1.72% | 0.42% |
| -ក្រៅប្រទេស | 266,240 | 312,551 | 17.39% | 1.28% | 0.32% |
| ២ ក្រសួងសាធារណការនិងដឹកជញ្ជូន | 2,411,049 | 2,472,277 | 2.54% | 10.14% | 2.49% |
| ចំណាយចរន្តសរុប | 388,160 | 399,444 | 2.91% | 1.64% | 0.40% |
| ចំណាយមូលធនសរុប | 2,022,889 | 2,072,834 | 2.47% | 8.50% | 2.09% |
| -ក្នុងប្រទេស | 495,000 | 540,000 | 9.09% | 2.22% | 0.54% |
| -ក្រៅប្រទេស | 1,527,889 | 1,532,834 | 0.32% | 6.29% | 1.55% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ៣ក្រសួងការពារជាតិ | 1,857,117 | 2,198,378 | 18.38% | 9.02% | 2.22% |
| ចំណាយចរន្តសរុប | 1,856,205 | 2,198,378 | 18.43% | 9.02% | 2.22% |
| ចំណាយមូលធនសរុប | 912 | 0 | -100.00% | 0.00% | 0.00% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 912 | 0 | -100.00% | 0.00% | 0.00% |
| ៤ក្រសួងសុខាភិបាល | 1,697,615 | 1,967,851 | 15.92% | 8.07% | 1.99% |
| ចំណាយចរន្តសរុប | 1,201,855 | 1,393,974 | 15.99% | 5.72% | 1.41% |
| ចំណាយមូលធនសរុប | 495,760 | 573,877 | 15.76% | 2.35% | 0.58% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 495,760 | 573,877 | 15.76% | 2.35% | 0.58% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ៥ក្រសួងមហាផ្ទៃ | 1,460,617 | 1,659,720 | 13.63% | 6.81% | 1.67% |
| ចំណាយចរន្តសរុប | 1,365,445 | 1,557,677 | 14.08% | 6.39% | 1.57% |
| ចំណាយមូលធនសរុប | 95,172 | 102,043 | 7.22% | 0.42% | 0.10% |
| -ក្នុងប្រទេស | 41,600 | 41,600 | 0.00% | 0.17% | 0.04% |
| -ក្រៅប្រទេស | 53,572 | 60,443 | 12.83% | 0.25% | 0.06% |
| ៦ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 759,396 | 890,826 | 17.31% | 3.65% | 0.90% |
| ចំណាយចរន្តសរុប | 749,763 | 887,312 | 18.35% | 3.64% | 0.90% |
| ចំណាយមូលធនសរុប | 9,634 | 3,514 | -63.52% | 0.01% | 0.00% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 9,634 | 3,514 | -63.52% | 0.01% | 0.00% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀប ច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 602,539 | 788,394 | 30.85% | 3.23% | 0.80% |
| ចំណាយចរន្តសរុប | 575,075 | 772,540 | 34.34% | 3.17% | 0.78% |
| ចំណាយមូលធនសរុប | 27,463 | 15,854 | -42.27% | 0.07% | 0.016% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 27,463 | 15,854 | -42.27% | 0.07% | 0.016% |
| ៨ ក្រសួងធនធានទឹក និងឧតុនិយម | 1,018,435 | 770,931 | -24.30% | 3.16% | 0.78% |
| ចំណាយចរន្តសរុប | 118,302 | 130,175 | 10.04% | 0.53% | 0.13% |
| ចំណាយមូលធនសរុប | 900,133 | 640,756 | -28.82% | 2.63% | 0.65% |
| -ក្នុងប្រទេស | 145,000 | 155,000 | 6.90% | 0.64% | 0.16% |
| -ក្រៅប្រទេស | 755,133 | 485,756 | -35.67% | 1.99% | 0.49% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ៩ក្រសួងរ៉ែ និងថាមពល | 413,097 | 752,650 | 82.20% | 3.09% | 0.76% |
| ចំណាយចរន្តសរុប | 46,402 | 49,998 | 7.75% | 0.21% | 0.05% |
| ចំណាយមូលធនសរុប | 366,695 | 702,652 | 91.62% | 2.88% | 0.71% |
| *-ក្នុងប្រទេស* | 0 | 0 | 0.00% | 0.00% | 0.00% |
| *-ក្រៅប្រទេស* | 366,695 | 702,652 | 91.62% | 2.88% | 0.71% |
| ១០ក្រសួងអភិវឌ្ឍន៍ជនបទ | 562,635 | 654,686 | 16.36% | 2.69% | 0.66% |
| ចំណាយចរន្តសរុប | 160,807 | 169,137 | 5.18% | 0.69% | 0.17% |
| ចំណាយមូលធនសរុប | 401,828 | 485,549 | 20.84% | 1.99% | 0.49% |
| *-ក្នុងប្រទេស* | 150,000 | 170,000 | 13.33% | 0.70% | 0.17% |
| *-ក្រៅប្រទេស* | 251,828 | 315,549 | 25.30% | 1.29% | 0.32% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| ១១ទីស្តីការគណៈរដ្ឋមន្ត្រី | 604,744 | 553,973 | -8.40% | 2.27% | 0.56% |
| ចំណាយចរន្តសរុប | 477,179 | 409,132 | -14.26% | 1.68% | 0.41% |
| ចំណាយមូលធនសរុប | 127,565 | 144,841 | 13.54% | 0.59% | 0.15% |
| *-ក្នុងប្រទេស* | 0 | 0 | 0.00% | 0.00% | 0.00% |
| *-ក្រៅប្រទេស* | 127,565 | 144,841 | 13.54% | 0.59% | 0.15% |
| ១២ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 439,480 | 426,576 | -2.94% | 1.75% | 0.43% |
| ចំណាយចរន្តសរុប | 220,187 | 245,009 | 11.27% | 1.01% | 0.25% |
| ចំណាយមូលធនសរុប | 219,292 | 181,567 | -17.20% | 0.74% | 0.18% |
| *-ក្នុងប្រទេស* | 50,000 | 40,000 | -20.00% | 0.16% | 0.04% |
| *-ក្រៅប្រទេស* | 169,292 | 141,567 | -16.38% | 0.58% | 0.14% |

# ចំណាយសរុបថវិកាថ្នាក់ជាតិតាមក្រសួង ឆ្នាំ២០១៨ (ត)

| គម្រោងចំណាយ | ២០១៧ ច្បាប់ | ២០១៨ ច្បាប់ | % កំណើនធៀបច្បាប់ ២០១៧ | % ចំណាយថវិការដ្ឋសរុប | %ផសស |
|---|---|---|---|---|---|
| **១៣ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **214,332** | **220,640** | **2.94%** | **0.91%** | **0.22%** |
| ចំណាយចរន្តសរុប | 189,759 | 209,359 | 10.33% | 0.86% | 0.21% |
| ចំណាយមូលធនសរុប | 24,573 | 11,281 | -54.09% | 0.05% | 0.01% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 24,573 | 11,281 | -54.09% | 0.05% | 0.01% |
| **១៤គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** | **180,945** | **208,524** | **15.24%** | **0.86%** | **0.21%** |
| ចំណាយចរន្តសរុប | 180,945 | 208,524 | 15.24% | 0.86% | 0.21% |
| ចំណាយមូលធនសរុប | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្នុងប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |
| -ក្រៅប្រទេស | 0 | 0 | 0.00% | 0.00% | 0.00% |

# ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន
# តាមលំដាប់ ធំបំផុតទាក់ (ចំណាយចរន្ត និង ចំណាយមូលធន)



# ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិកឆ្នាំ២០១៨
# តាមលំដាប់ក្រសួង ពីធំ ទៅ តូច



# ទំហំកំណើនចំណាយចរន្តថ្នាក់ជាតិតាមក្រសួងឆ្នាំ២០១៨
## ធៀបច្បាប់ឆ្នាំ ២០១៧ តាមលំដាប់ ពីធំ ទៅ តូច



# កំណើនចំណាយចរន្តជាភាគរយតាមក្រសួងឆ្នាំ ២០១៨ ធៀបច្បាប់ឆ្នាំ ២០១៧ តាមលំដាប់ ពីធំ ទៅ តូច



# កំណើនចំណាយសរុបតាមវិស័យរងាន ឆ្នាំ ២០១៣ និង ឆ្នាំ ២០១៨



# ចំណាយសរុបតាមវិស័យជា % ផ.ស.ស. រវាងឆ្នាំ ២០១៣ និង ឆ្នាំ ២០១៨



# កំណើនចំណាយចរន្តតាមវិស័យជា % ផ.ស.ស.
# រវាងឆ្នាំ ២០១៣ និង ឆ្នាំ ២០១៨



# វិស័យសង្គមកិច្ចត្រូវបានចាត់ទុកជាវិស័យអាទិភាពទីមួយ

**ទំហំ ៣៧% ផ្តល់អាទិភាពចំណាយទៅលើ÷**

- ❖ គាំទ្រដល់ការពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ, ការអប់រំកាយ និងកីឡា ជាពិសេសការបន្តកែទម្រង់ក្នុងវិស័យអប់រំ, ពន្លឿនការអភិវឌ្ឍវិស័យអប់រំ និង ជំរុញអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ
- ❖ បន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ជាពិសេស គោលនយោបាយបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ជាពិសេស ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យការងារស្របតាមគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥
- ❖ បន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាសុខាភិបាល
- ❖ បន្តគាំទ្រដល់ការងារទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ, គាំទ្រដល់ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- ❖ គាំទ្រដល់មជ្ឈមណ្ឌលជាតិថែទាំមនុស្សចាស់ មជ្ឈមណ្ឌលជនវិបល្លាសស្មារតី និងការបន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន
- ❖ គាំទ្រដល់កិច្ចដំណើរការរោងចក្រផលិតឧបករណ៍សិប្បនិម្មិត
- ❖ បន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ❖ បន្តគាំទ្រដល់ការអភិរក្ស និងការអភិវឌ្ឍប្រាសាទបុរាណនានា
- ❖ គាំទ្រដល់ការសិក្សាស្រាវជ្រាវ និងការចងក្រងឯកសារស្តីពីសម្បត្តិវប្បធម៌អរូបី រួមទាំងការបន្តគាំទ្រដល់ការបណ្តុះបណ្តាល និងការអភិរក្ស វិស័យសិល្បៈបុរាណដល់សិស្សជំនាន់ក្រោយ និង
- ❖ បន្តលើកស្ទួយសុខដុមនីយកម្មសាសនានៅកម្ពុជា។

# ការឧបត្ថម្ភពីថវិការដ្ឋដល់មន្ទីរពេទ្យគន្ធបុប្ផា ដល់ប្រមាណ ១៥ លានដុល្លារ

ឯកតា លានរៀល



# វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

**ទំហំ ២៦% ផ្តល់អាទិភាពចំណាយទៅលើ÷**

- បន្តបង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ, ការពង្រឹងគោលការណ៍នីតិរដ្ឋក្នុងលទ្ធិប្រជាធិបតេយ្យសេរី, ការធានាយុត្តិធម៌សង្គម
- បន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ, បង្កើនការគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខមាលភាពកងកម្លាំងប្រដាប់អាវុធ រួមទាំងការហ្វឹកហ្វឺន និងការបំពាក់មធ្យោបាយចាំបាច់នានា
- គាំទ្រដល់ការសាងសង់ទីលានហ្វឹកហ្វឺន សម្រាប់បម្រើឱ្យការហ្វឹកហ្វឺនផង និងសម្រាប់ត្រៀមទទួលធ្វើជាម្ចាស់ផ្ទះនូវព្រឹត្តិការណ៍បាញ់គ្រាប់ពិត ទាំងកម្រិតតំបន់ និងអន្តរជាតិផង
- បន្តបង្កើនការគាំទ្រដល់ការបណ្តុះបណ្តាលមន្ត្រីនគរបាល និងមន្ត្រីពន្ធនាគារ
- បន្តគាំទ្រដល់ការផលិតលិខិតឆ្លងដែន និងប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បន្តគាំទ្រដល់កិច្ចការសន្តិសុខជាតិ, ការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន, គាំទ្រការរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន
- បន្តគាំទ្រដល់ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និង
- បង្កើនការគាំទ្រដល់គណៈកម្មាធិការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងផ្តល់ការគាំទ្រដល់ការពង្រឹងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន។

# វិស័យរដ្ឋបាលទូទៅ

ទំហំ ១៥% ផ្តល់អាទិភាពចំណាយទៅលើ៖

- ❖ គាំទ្រដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦
- ❖ បន្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨
- ❖ គាំទ្រដល់អន្តរាគមន៍ដោយផ្ទាល់របស់រដ្ឋ ទាំងក្នុងវិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច
- ❖ បន្តគាំទ្រដល់ការបែងចែកដីសម្បទានសង្គមកិច្ច និងការដោះស្រាយទំនាស់ដីធ្លី
- ❖ ជំរុញការបន្តចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ជនជាតិដើមភាគតិច
- ❖ បន្តគាំទ្រនិងពង្រឹងការងារសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥
- ❖ បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ❖ បន្តគាំទ្រដល់អគ្គលេខាធិការរដ្ឋសភា និងព្រឹទ្ធសភា សម្រាប់អនុវត្តនូវមុខងាររបស់ខ្លួន
- ❖ បន្តគាំទ្រដល់សវនកម្មផ្ទៃក្រៅ ដើម្បីរួមចំណែកលើកស្ទួយអភិបាលកិច្ច និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ❖ គាំទ្រដល់កិច្ចដំណើរការរបស់វិទ្យាស្ថានការទូត និងការសិក្សាអន្តរជាតិ។

# វិស័យសេដ្ឋកិច្ច

ទំហំ ១០% ផ្តល់អាទិភាពចំណាយទៅលើ÷

- បន្តលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ក្នុងវិស័យកសិកម្ម
- បន្តផ្តល់អាទិភាពលើការជួសជុល ថែទាំផ្លូវ ស្ពាន ប្រព័ន្ធធារាសាស្ត្រ និងផ្លូវលំជនបទ
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម ព្រមទាំងការបន្តជំរុញការដាំដុះបន្លែ
- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច, ការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ និងការស្តារព្រៃឈើឡើងវិញ, និង ជលផល
- បង្កើនការគាំទ្រដល់ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- គាំទ្រដល់ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការមេ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធឡូជីស្ទីក
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍ និងជួយបង្កើនតម្លៃបន្ថែម
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បន្តពង្រឹងការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- បន្តពង្រឹងនូវយន្តការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម
- បន្តអភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ រួមទាំងពង្រឹងការអនុវត្ត និង
- បន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទូរគមនាគមន៍។

# កំណើនថវិការបស់ក្រសួង ស្ថាប័ន សំខាន់ៗ រវាងឆ្នាំ ២០១៣ និង ឆ្នាំ ២០១៨

ឯកតា លានរៀល

| ក្រសួង ស្ថាប័ន | ២០១៣ អនុវត្ត | ២០១៨ ច្បាប់ | កំណើនជាលានរៀល | កំណើនជាភាគរយ |
|---|---|---|---|---|
| **ក្រសួងសុខាភិបាល** | 903,510 | 1,967,851 | 1,064,341 | 118% |
| ចំណាយចរន្ត | 853,829 | 1,393,974 | 540,145 | 63% |
| បន្ទុកបុគ្គលិក | *157,588* | *466,148* | *308,560* | *196%* |
| មិនមែនបន្ទុកបុគ្គលិក | *696,241* | *927,826* | *231,585* | *33%* |
| ចំណាយមូលធន | 49,681 | 573,877 | 524,196 | 1055% |
| **ក្រសួងអប់រំ យុវជន និងកីឡា** | 1,083,520 | 3,438,008 | 2,354,488 | 217% |
| ចំណាយចរន្ត | 1,056,557 | 2,705,457 | 1,648,900 | 156% |
| បន្ទុកបុគ្គលិក | *784,993* | *2,180,747* | *1,395,753* | *178%* |
| មិនមែនបន្ទុកបុគ្គលិក | *271,563* | *524,710* | *253,147* | *93%* |
| ចំណាយមូលធន | 26,963 | 732,551 | 705,588 | 2617% |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | 496,069 | 890,826 | 394,757 | 80% |
| ចំណាយចរន្ត | 399,282 | 887,312 | 488,030 | 122% |
| បន្ទុកបុគ្គលិក | *347,483* | *810,561* | *463,078* | *133%* |
| មិនមែនបន្ទុកបុគ្គលិក | *51,800* | *76,752* | *24,952* | *48%* |
| ចំណាយមូលធន | 96,787 | 3,514 | -93,272 | -96% |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | 124,725 | 220,640 | 95,915 | 77% |
| ចំណាយចរន្ត | 101,213 | 209,359 | 108,146 | 107% |
| បន្ទុកបុគ្គលិក | *30,021* | *96,501* | *66,480* | *221%* |
| មិនមែនបន្ទុកបុគ្គលិក | *71,193* | *112,858* | *41,665* | *59%* |
| ចំណាយមូលធន | 23,512 | 11,281 | -12,231 | -52% |

# កំណើនថវិការបស់ក្រសួង ស្ថាប័ន សំខាន់ៗ រវាងឆ្នាំ ២០១៣ និង ឆ្នាំ ២០១៨ (ត)

ឯកតា លានរៀល

| ក្រសួង ស្ថាប័ន | ២០១៣ អនុវត្ត | ២០១៨ ច្បាប់ | កំណើនជាលានរៀល | កំណើនជាភាគរយ |
|---|---|---|---|---|
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | 155,705 | 426,576 | 270,871 | 174% |
| ចំណាយចរន្ត | 117,848 | 245,009 | 127,161 | 108% |
| បន្ទុកបុគ្គលិក | *47,588* | *121,818* | *74,230* | *156%* |
| មិនមែនបន្ទុកបុគ្គលិក | *70,260* | *123,192* | *52,931* | *75%* |
| ចំណាយមូលធន | 37,857 | 181,567 | 143,710 | 380% |
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | 566,093 | 654,686 | 88,593 | 16% |
| ចំណាយចរន្ត | 109,036 | 169,137 | 60,101 | 55% |
| បន្ទុកបុគ្គលិក | *12,215* | *27,842* | *15,627* | *128%* |
| មិនមែនបន្ទុកបុគ្គលិក | *96,822* | *141,295* | *44,473* | *46%* |
| ចំណាយមូលធន | 457,057 | 485,549 | 28,493 | 6% |
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | 2,462,053 | 2,472,277 | 10,224 | 0.4% |
| ចំណាយចរន្ត | 53,836 | 399,444 | 345,607 | 642% |
| បន្ទុកបុគ្គលិក | *31,730* | *83,764* | *52,034* | *164%* |
| មិនមែនបន្ទុកបុគ្គលិក | *22,107* | *315,680* | *293,573* | *1328%* |
| ចំណាយមូលធន | 2,408,217 | 2,072,834 | -335,383 | -14% |
| **ក្រសួងធនធានទឹក និងឧតុនិយម** | 1,212,488 | 770,931 | -441,556 | -36% |
| ចំណាយចរន្ត | 56,079 | 130,175 | 74,096 | 132% |
| បន្ទុកបុគ្គលិក | *9,596* | *27,109* | *17,513* | *182%* |
| មិនមែនបន្ទុកបុគ្គលិក | *46,483* | *103,066* | *56,583* | *122%* |
| ចំណាយមូលធន | 1,156,408 | 640,756 | -515,652 | -45% |

## ២ ក្របខណ្ឌថវិកាឆ្នាំ ២០១៨

### ២.៣ សន្និធិបំណុលសាធារណៈក្រៅប្រទេស

**ធនាធិបតេយ្យភាពនៃការគ្រប់គ្រងបំណុលសាធារណៈ**

# សន្និធិបំណុលសាធារណៈក្រៅប្រទេស ត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០១៧




*សរុប 6,233.2 លានដុល្លារអាមេរិក*

# សន្និធិបំណុលសាធារណៈក្រៅប្រទេស (២០១២-២០១៨)



# អនុបាតបំណុលគន្លឹះទាំង ០៥

### អនុបាតសន្និធិបំណុលធៀបនឹង ផសស




### អនុបាតសន្និធិបំណុលធៀបនឹងការនាំចេញ




### អនុបាតសន្និធិបំណុលធៀបនឹងចំណូលថវិកាជាតិ




### អនុបាតសេវាបំណុលធៀបនឹងការនាំចេញ




### អនុបាតសេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




- តម្លៃចារឹកនៃសន្និធិបំណុល
- តម្លៃបច្ចុប្បន្ននៃសន្និធិបំណុល
- សេវាបំណុល
- អនុបាតគោល

# គោលការណ៍គន្លឹះទាំង ០៤ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ

ការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍ គន្លឹះចំនួន ០៤ ដូចខាងក្រោម÷

(១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

(២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

(៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

(៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

# ២ ក្របខណ្ឌថវិកាឆ្នាំ ២០១៨

## ២.៤ គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

បង្កើនឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និង ប្រសិទ្ធភាពរដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ

# គម្រោងថវិកាថ្នាក់ក្រោមជាតិ ឆ្នាំ២០១៨

| ថវិកាថ្នាក់ក្រោមជាតិ | 2017 ច្បាប់ | 2018 គម្រោង | % កំណើនធៀបច្បាប់ ២០១៧ | % ផសស |
|---|---|---|---|---|
| **ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ** | **967,528** | **946,804** | **-2.1%** | **0.96%** |
| ចំណូលសារពើពន្ធ | 926,300 | 910,443 | -1.7% | 0.92% |
| ចំណូលមិនមែនសារពើពន្ធ | 41,228 | 36,361 | -11.8% | 0.04% |
| **សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ** | **1,605,714** | **1,684,674** | **4.9%** | **1.70%** |
| ចំណាយចរន្ត | 1,386,579 | 1,465,122 | 5.7% | 1.48% |
| ចំណាយមូលធន | 219,135 | 219,552 | 0.2% | 0.22% |
| **ឱនភាពថវិកា** | **-638,186** | **-737,870** | **15.6%** | **-0.74%** |
| **ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ** | **638,186** | **737,870** | **15.6%** | **0.74%** |
| រាជធានី-ខេត្ត | 128,710 | 148,814 | 15.6% | 0.15% |
| មូលនិធិក្រុង-ស្រុក | 134,073 | 155,015 | 15.6% | 0.16% |
| មូលនិធិឃុំ-សង្កាត់ | 375,403 | 434,041 | 15.6% | 0.44% |

# គម្រោងថវិកាថ្នាក់ក្រោមជាតិ ឆ្នាំ២០១៨



# តុល្យភាពថវិការដ្ឋឆ្នាំ ២០១៨

- **អតិរេកចរន្ត÷**
  - **គម្រោងឆ្នាំ ២០១៨:** គ្រោងអតិរេកចរន្ត ឱ្យបានក្នុងកម្រិតប្រមាណ ២,៤៨% នៃ ផសស ធៀបច្បាប់ឆ្នាំ ២០១៧ ដែលបានគ្រោង ២,៩៨% នៃ ផសស ។
- **ឱនភាពថវិកាសរុប÷**
  - ឱនភាពថវិកាសរុបឆ្នាំ ២០១៨ ស្មើនឹង -៥,៨៤% នៃ ផសស ដែលកើនឡើងពី -៥,០៧% នៃ ផសស នៃច្បាប់ឆ្នាំ ២០១៧
  - ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេស ៤,៥៩% នៃ ផសស និងមូលនិធិទ្រទ្រង់ថវិកា ០,២៥% នៃ ផសស និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលប្រមាណ ១,០% នៃ ផសស ។

# ៣ បញ្ហាប្រឈម និង វិធានការ ក្នុងការអនុវត្តថវិកាឆ្នាំ ២០១៨

បានរៀបចំឡើងតាមគោលនយោបាយវិភាគកម្មថវិកាដោយប្រយ័ត្នប្រយែង
ដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើមនុស្ស

# ៣.១. បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

**ផ្នែកចំណូល**

- ចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយ
- ការប្រមូលចំណូលឈានទៅកៀកនឹងពិដាននៃសក្តានុពល
- ចំណូលពន្ធគយក៏កាន់តែមានការធ្លាក់ចុះច្រើន
- វប្បធម៌នៃការបង់ពន្ធនៅមានកម្រិត
- កិច្ចសហការផ្តល់ព័ត៌មានរវាងអន្តរស្ថាប័ន

**ផ្នែកចំណាយ**

- ការកើនឡើងខ្លាំងនៃចំណាយបន្ទុកបុគ្គលិក
- ការបង្កើនចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង
- ការឈានឡើងរបស់កម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប
- សមត្ថភាពស្ថាប័ននៅមានកម្រិត

# ៣.២. វិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

## ក. វិធានការជារួម

(១)-វិធានការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានពីហានិភ័យខាងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច;

(២)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណូល;

(៣)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណាយ, ទាំងផ្នែករៀបចំ និង ផ្នែកអនុវត្តថវិកា; និង

(៤)-ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "ដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០", ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ឆ្នាំ ២០១៨-២០២៥ , ការអនុវត្តកម្មវិធីការកែទម្រង់រដ្ឋបាលសាធារណៈ, ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

# ៣.២. វិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ (ត)

## ខ. វិធានការពន្ធដារ

**១. ធ្វើការលុបចោលពន្ធសត្តឃាត** ដើម្បីជួយលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

**២. ធ្វើការកែសម្រួលមាត្រា៤៧ថ្មី (មួយ)** នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីផ្តល់ការអនុគ្រោះដល់មន្ត្រីរាជការ និងកម្មករនិយោជិត ដែលមានប្រាក់បៀវត្ស ១ ២០០ ០០០ រៀល ឬ តិចជាង ដោយមិនជាប់ពន្ធលើប្រាក់បៀវត្ស។

**៣. ការបញ្ចូលបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ**ក្នុងច្បាប់ស្តីពីសារពើពន្ធ ដើម្បីជួយពង្រឹងការគ្រប់គ្រងវិស័យប្រេងកាត និងធនធានរ៉ែ ប្រកបដោយប្រសិទ្ធភាព។



# ៤ សន្និដ្ឋាន




## ថវិកាឆ្នាំ ២០១៨



ត្រូវបានប្រសិទ្ធនាមថា “ជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និង ធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោកដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព ស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរ ក្នុងនីតិកាល បន្តបន្ទាប់ទៀត”